# ទំនុកដំកើង ២២
# ម្នាក់ដែលគេបានបោះបង់ចោលនាំឲ្យមនុស្សជាច្រើនមានអំណរ

អ្នកនិពន្ធ រុហ្វ លេភិឡារ

**សេចក្តីផ្តើម**

ទំនុកដំកើងនេះពិតជាទំនុកដំកើងសំខាន់ខ្លាំងមួយក្នុងការជួយយើងឲ្យយល់អំពីការសុគតរបស់ព្រះយេស៊ូវនៅលើឈើឆ្កាង។ ជាដំបូងដាវីឌបានសរសេរទំនុកដំកើងនេះនៅពេលគាត់ស្ថិតក្នុងស្ថានភាពលំបាកមួយ បើទោះជាយើងដឹងមិន() ច្បាស់ថាស្ថានភាពមួយណាដែលទំនុកដំកើងនេះសំដៅទៅកាន់ក៏ដោយ។ ទោះបើដាវីឌបានសរសេរទំនុកដំកើងនេះ ក៏ទំនុកដំកើងនេះចង្អុលទៅកាន់ការរងទុក្ខនិងការរស់ឡើងវិញរបស់ព្រះយេស៊ូវដែរ។ នៅក្នុងកិច្ចការ ២:២៥-៣១ ពេត្រុសដកស្រង់ពីទំនុកដំកើង ១៦ ហើយថ្លែងថា ដាវីឌគឺជាហោរាម្នាក់ដែលបានដឹងជាមុនអំពីព្រះគ្រីស្ទ។ យើងអាចនិយាយដូចគ្នាអំពីទំនុកដំកើងនេះផងដែរ។ ទំនុកដំកើងនេះប្រមើលអំពីសម្រែករបស់ព្រះគ្រីស្ទពីលើឈើឆ្កាង (ម៉ាថាយ ២៧:៤៦) ការឡកឡឺយដែលទ្រង់ទទួល (លូកា ២៣:៣៥) ការឈឺចាប់និងសម្រែករបស់ទ្រង់ (យ៉ូហាន ១៩:២៨) ការចាក់ទំលុះដៃជើងរបស់ទ្រង់ (យ៉ូហាន ១៩:៣៤-៣៧) ហើយនិងការចាប់ឆ្នោតសំរាប់អាវរបស់ទ្រង់ (យ៉ូហាន ១៩:២៣-២៤)។ វាក៏ទន្ទឹងចាំដល់ជ័យជំនះរបស់ទ្រង់និងមនុស្សទាំងអស់ពីគ្រប់ជាតិសាសន៍មកចុះចូលចំពោះទ្រង់ផងដែរ។

**រចនាសម្ព័ន្ធ**

ទំនុកដំកើងនេះដើរតាមគំរូរបស់ទំនុកដំកើងជាច្រើនដែលចាប់ផ្តើមដោយសម្រែកឲ្យជួយហើយបញ្ចប់នៅក្នុងការជានាសង្គ្រោះជាមួយនឹងសេចក្តីសន្យាបំពេញសំរេចសម្បថ។ គម្រោងគ្រឹះនៃរចនាសម្ព័ន្ធគឺៈ

**ខ. ១-១០ ការរងទុក្ខ**

- ខ. ១-៥ សេចក្តីអធិស្ឋានដែលមិនត្រូវបានឆ្លើយតប
- ខ. ៦-៩ ការទុកចិត្តដែលមិនត្រូវបានផ្តល់រង្វាន់

**ខ. ១១-២១** សេចក្តីអង្វរឲ្យព្រះនៅជិតនិងជួយសង្គ្រោះ

**ខ. ២២-៣១** ពិធីបុណ្យសរសើរតម្កើងជាសកលមួយ

**សេចក្តីអត្ថាធិប្បាយ**

**ខ. ១-២** ពាក្យចាប់ផ្តើមប្រកាសអំពីអ្វីដែលហាក់ដូចជាការផ្ទុយគ្នាមួយ។ អ្នកនិពន្ធទំនុកដំកើងមិនគ្រាន់តែនិយាយថា «ព្រះ» ប៉ុន្តែ «ព្រះនៃទូលបង្គំ» ដែលបញ្ជាក់អំពីទំនាក់ទំនងមួយហើយនិងការទទួលស្គាល់ទំនាក់ទំនងនោះ ប៉ុន្តែនៅក្នុងទំនាក់ទំនងនោះគាត់ថ្លែងថា ព្រះរបស់គាត់បានបោះបង់គាត់ចោល។ ទោះបីអ្នករងទុក្ខស្រែកអំពាវនាវទៅកាន់ព្រះ ក៏ព្រះមិនឆ្លើយតបនឹងសេចក្តីអធិស្ឋានរបស់គាត់ដែរ។ ទោះបីមានការឈឺចាប់ អ្នកនិពន្ធទំនុកដំកើងនៅតែទុកចិត្តលើព្រះ។ គាត់មិនដាក់បណ្តាសារឬបដិសេធព្រះឡើយ។ គាត់ដឹងថាព្រះអម្ចាស់គឺបរិសុទ្ធ សុចរិត និងសោយរាជ្យជាស្តេច។ ព្រះយេស៊ូវបានដកស្រង់ខ. ១ នៅពេលទ្រង់កំពុងសុគតនៅលើឈើឆ្កាង (ម៉ាថាយ ២៧:៤៦, ម៉ាកុស ១៥:៣៤) ដែលបង្ហាញថាជាចុងក្រោយអត្ថបទនេះសំដៅទៅកាន់ទ្រង់ផ្ទាល់។ ព្រះយេស៊ូវគឺជាគំរូរបស់យើងដែលទ្រង់បានរក្សាសេចក្តីជំនឿរបស់ទ្រង់បើទោះជានៅក្នុងការរងទុក្ខរបស់ទ្រង់ក៏ដោយ ព្រះអម្ចាស់នៅតែជាព្រះ*របស់ខ្ញុំ*។ ទំនុកដំកើង ៣៧:២៥ ថ្លែងថា គាត់មិនដែលឃើញមនុស្សសុចរិតត្រូវគេបោះបង់ចោលទេ ប៉ុន្តែព្រះអង្គសុចរិតនេះ*ត្រូវបានគេបោះបង់ចោល* ហើយត្រឡប់ជាបណ្តាសាជំនួសយើង (កាឡាទី ៣:១៣)។ ដោយសារតែទ្រង់ត្រូវបានគេបោះបង់ចោលសំរាប់យើង នោះយើងអាចចូលមកឯព្រះដោយអំណរ (ខ. ២២-៣១)។

**ខ. ៣** ទោះបីព្រះមិនបានឆ្លើយតបក៏ដោយ ក៏អ្នកនិពន្ធនៅតែទទួលស្គាល់ថាព្រះគឺបរិសុទ្ធ គឺទ្រង់សមនឹងទទួលការសរសើរតម្កើងនិងការទុកចិត្ត។

**ខ. ៤-៥** អ្នកនិពន្ធបានរំលឹកឡើងវិញថាព្រះបានសង្គ្រោះនិងរំដោះអ្នកផ្សេងនៅក្នុងអតីតកាល ដូច្នេះកង្វះខាតជំនួយពីព្រះគឺផ្ទុយនឹងបទពិសោធន៍របស់មនុស្សជំនាន់មុនៗ។

**ខ. ៦-៨** *ពួកឰយុកោ* បានទុកចិត្តនិងអធិស្ឋានហើយព្រះអង្គបានសង្គ្រោះពួកគេ (ខ. ៤, ៥) ដូច្នេះអ្នកនិពន្ធនៅទីនេះកត់សំគាល់ថាគាត់បានទុកចិត្តព្រះដែរ ប៉ុន្តែព្រះមិនបានសង្គ្រោះគាត់ទេ។ ការទុកចិត្តបានធ្វើឲ្យគាត់ក្លាយជាត្មះតិះដៀល (ខ. ៦-៨)។ អ្នករងទុក្ខពិពណ៌នាខ្លួនឯងគាត់ជា «ដង្កូវ» គ្មានតំលៃនិងសារៈសំខាន់។ គាត់ត្រូវគេមើលងាយ សើចចំអកជេរប្រមាថ ឡកឡឺយ។ តែគាត់មិនដែលអាណិតខ្លួនឯង មិនដែលបន្ទោសខ្លួនឯងដោយព្រោះវាសនារបស់គាត់ហើយមិនដែលចង់សងសឹកនោះឡើយ។ ព្រះយេស៊ូវ បានអាណិតដល់អ្នកដទៃផងដែរនៅពេលទ្រង់បានមានបន្ទូល «ឲ្យយំនឹងខ្លួនអ្នករាល់គ្នា ហើយនឹងកូនចៅរបស់អ្នករាល់គ្នាចុះ» (លូកា ២៣.២៨)។ ពាក្យនៅក្នុងខ. ៧និង៨ ត្រូវបាននិយាយឡើងវិញនៅឯកាល់វ៉ារី (ម៉ាថាយ ២៧.៣៩, ៤៣)។

**ខ. ៩-១០** សូម្បីតែ ការសម្រាលបុត្រដែលហាក់ដូចជាមកពីសកម្មភាពរបស់មនុស្សក៏ជាអ្វីដែលព្រះធ្វើដែរ។ ម្តាយរបស់យើងផ្តល់កំណើតដល់យើង ប៉ុន្តែខនេះនិយាយថា ព្រះគឺជាអង្គទ្រង់ដែលយកយើងចេញពីផ្ទៃម្តាយ។ សេចក្តីពិតដែលថាព្រះប្រទានសំរាប់យើងចាប់ពីពេលយើងនៅក្នុងផ្ទៃផ្តល់មូលហេតុត្រឹមត្រូវឲ្យយើងទុកចិត្តដល់ទ្រង់។

**ខ. ១១-២១** ផ្នែកនេះមានការអំពាវនាវពីរសំរាប់ឲ្យព្រះយាងមកជិតនិងជួយសង្គ្រោះ (ខ. ១១ក, ១៩-២១ក*)* ការអំពាវនាវទីមួយនៅក្នុងខ. ១១ក មានបន្ទាប់ដោយការពិពណ៌នាអំពីទុក្ខលំបាកដែលអ្នករងទុក្ខកំពុងជួបប្រទះ។ ការអំពាវនាវទីពីរ (ខ. ១៩-២១ក*)* ទទួលស្គាល់កម្លាំងរបស់ព្រះអម្ចាស់ (ខ.១៩) ប៉ុន្តែសេចក្តីស្លាប់កំពុងមកដល់(*ដាវ*, ខ. ២០) នាំមកនូវការបញ្ចប់ដ៏សាហាវ (*ឆ្កែ សិង្ហ...គោព្រៃ*, ខ. ២០, ២១)។ បន្ទាប់មកគ្រប់យ៉ាងផ្លាស់ប្តូរនៅពេលព្រះបានឆ្លើយតបនឹងសេចក្តីអធិស្ឋាន (ខ. ២១ខ)។

**ខ. ១១** ក្នុងគ្រប់ទាំងអ្វីដែលកំពុងកើតឡើងចំពោះគាត់ អ្នកនិពន្ធបន្តស្រែកហៅព្រះសំរាប់ការសង្គ្រោះចេញពីពួកខ្មាំងសត្រូវដែលនៅព័ទ្ធជុំវិញគាត់។

**ខ. ១២-២០** នេះពណ៌នាអំពីអត្តចរិតធម្មតារបស់មនុស្សគឺ អ្នកខ្លាំងកៀបសង្កត់អ្នកខ្សោយ មនុស្សច្រើនកៀបសង្កត់មនុស្សម្នាក់។ ទំនុកដំកើងប្រើរូបភាពអំពីសត្វសាហាវ (គោឈ្មោល សិង្ហ ឆ្កែ គោព្រៃ*)* ដើម្បីពណ៌នាអំពីអ្នកគ្នាច្រើនប៉ុន្តែអ្នកគ្នាច្រើនគឺជាមនុស្សជាតិ។

**ខ. ១២** *គោឈ្មោលយ៉ាងខ្លាំងពីស្រុកបាសាន។* បាសានគឺតំបន់ដីមានជីជាតិនៅខាងកើតទន្លេយ័រដាន់ ល្បីខាងសត្វចៀមនិងសត្វគោធំៗ។ នៅបាសានមានការចិញ្ចឹមសត្វគោកាចសាហាវដែលមិនគេផ្សាំងដែលដើរចុះឡើងដោយសេរីនិងគ្រោះថ្នាក់។

**ខ. ១៤-១៥** ខទាំងនេះបរិយាយអំពីភាពនឿយហត់និងភាពខ្សោយដែលគ្មានសង្ឃឹម។ យើងឃើញថាដាវីឌមិនមែនជាថ្មដាដែលរើមិនបាននោះទេ ប៉ុន្តែគាត់ត្រូវរញ្ជួយដោយសារបញ្ហានិងសេចក្តីល្បួងផ្សេងៗ។

*ឆ្អឹង «សណ្តាកចេញពីគ្នា»*។ «សណ្តាកចេញពីគ្នា» ភាសាហេព្រើរ «ត្រូវខ្ចាត់ខ្ចាយទៅ» (យ៉ូប ៤.១១, ៤១.១៧, ទំនុកដំកើង ៩២:៩)ហើយអាចសំដៅទៅលើក្រុមសត្វដែលស៊ីសាច់ជាអាហារមួយដូចជាឆ្កែចចកបានស៊ីត្របាក់សត្វមួយជាចំណីហើយសមាជិកនៃក្រុមពាំយកចំណែកសាច់របស់ពួកវាចេញទៅ។

*អណ្តាតរបស់ទូលបង្គំជាប់នៅក្រអូមមាត់*។ យើងដឹងថាទុក្ខព្រួយហួសហេតុពេកធ្វើឲ្យស្ងួតសំណើមស្ទើរតែទាំងអស់នៅក្នុងរាងកាយរបស់យើង ហើយវាបណ្តាលឲ្យមាត់របស់យើងស្ងួត។ អ្នកខ្លះមើលឃើញអំពីទំនាក់ទំនងគ្នាមួយនៅទីនេះរវាងខនេះនិងសម្រែកនៃការស្រេកទឹករបស់ព្រះយេស៊ូវពីលើឈើឆ្កាង។

*ទ្រង់បាននាំទូលបង្គំចុះទៅក្នុងធូលីនៃសេចក្តីស្លាប់* ទោះបីជាពួកខ្មាំងសត្រូវរបស់គាត់សម្លាប់គាត់ក៏ដោយ ក៏នៅទីនេះអ្នកនិពន្ធថ្លែងថា ជាចុងក្រោយគឺជា*ព្រះ*ដែលនាំគាត់ទៅក្នុងធូលីនៃសេចក្តីស្លាប់។ សេចក្តីពិតសំខាន់មួយដែលព្រះយេស៊ូវ

បានបង្រៀននៅមុនការសុគតរបស់ទ្រង់គឺថា ទោះបើមនុស្សបាន សម្លាប់ទ្រង់ក៏ដោយ ក៏ជាចុងក្រោយគឺជាការស្តាប់បង្គាប់របស់ទ្រង់ចំពោះបំណងព្រះហឫទ័យរបស់ព្រះវរបិតានៅស្ថានសួគ៌ទេដែលបាននាំទៅដល់ការសុគតរបស់ទ្រង់។

**ខ. ១៦** *ឆ្កែ* នៅក្នុងបទគម្ពីរនេះឆ្កែគឺជានិមិត្តរូបនៃពួកអ្នកប្រព្រឹត្តអាក្រក់។ ឆ្កែជារឿយៗជាសត្វស៊ីសាកសពស្អុយ ទៅណាមកណាជាក្រុមនៅជាយក្រុង (ទំនុកដំកើង ៥៩:៦, ១៤) ហើយស៊ីសាកសពស្អុយនៅក្នុងក្រុង (១ពង្សាវតាក្សត្រ ១៤:១១)។ ដោយសារហេតុផលនេះ ជារឿយៗព្រះគម្ពីរបានប្រើពាក្យ *ឆ្កែ* ដើម្បីពណ៌នាអំពីមនុស្សអាក្រក់។

សំរាប់ *បានចាក់ទំលុះ* សូមមើលយ៉ូហាន ១៩.៣៤-៣៧។

**ខ. ១៧** ខនេះប្រហែលពណ៌នាថា តាមរយៈការរងទុក្ខរបស់គាត់ អ្នកនិពន្ធបានត្រឡប់ជាស្គមយ៉ាងណា។ ក្នុងលក្ខខ័ណ្ឌនេះពួកខ្មាំងសត្រូវរបស់គាត់មិនអាណិតគាត់ទេ ប៉ុន្តែសើចសប្បាយដាក់គាត់។

**ខ. ១៨** យ៉ូហាន ១៩.២៣-២៤ បង្ហាញយ៉ាងច្បាស់ថា ខនេះគឺជាទំនាយមួយទាក់ទងនឹងអ្វីដែលនឹងកើតឡើងចំពោះព្រះមែស៊ី។ វាមានប្រយោជន៍ក្នុងការយល់នូវអ្វីដែលអត្ថបទនេះកំពុងនិយាយនៅក្នុងបរិបទផ្ទាល់របស់វា។ ដាវីឌកំពុងនិយាយថា សម្ភារៈទាំងអស់របស់គាត់គឺជារំពាចំពោះពួកខ្មាំងសត្រូវរបស់គាត់ ដូចជាអ្នកច្បាំងឈ្នះបែងចែករបឹប *(រំហក)* របស់អ្នកច្បាំងចាញ់ជាមួយគ្នាដោយចាប់ឆ្នោតដើម្បីកំណត់ចំណែកដែលជារបស់ម្នាក់ៗ។ ដូច្នេះ ខនេះគឺជារូបភាពមួយអំពីមនុស្សម្នាក់ដែលត្រូវចាញ់ពួកខ្មាំងសត្រូវ ឬត្រូវស្លាប់ ដូច្នេះហើយទ្រព្យសម្បត្តិរបស់គាត់កំពុងត្រូវបានពួកអ្នកច្បាំងឈ្នះចែកគ្នា។ វាគឺជារូបភាពអំពីភាពគ្មានសង្ឃឹម ភាពគ្មានអំណាច និងការចាញ់គ្រប់យ៉ាង។ ដូច្នេះ វាគឺជាភាពផ្ទុយមួយយ៉ាងខ្លាំងទៅនឹងអ្វីដែលនឹងកើតឡើងនៅពេលព្រះឆ្លើយតបសេចក្តីអធិស្ឋានរបស់គាត់។

**ខ. ១៩-២០** ទោះបើស្ថានភាពរបស់ដាវីឌហាក់ដូចជាគ្មានសង្ឃឹមដូចជារូបភាពដែលមានក្នុងខ. ១៨ ក៏ដោយ ក៏ គាត់នៅតែទុកចិត្តលើព្រះហើយនិងអធិស្ឋានសូមឲ្យមានសេចក្តីសង្គ្រោះដែរ។ នេះគឺជាគំរូនៃសេចក្តីជំនឿដែលអត់ធ្មត់ដ៏អស្ចារ្យមួយ។

**ខ. ២១** អ្នករងទុក្ខកំពុងអធិស្ឋានសូមឲ្យមានសេចក្តីសង្គ្រោះ ហើយបន្ទាប់មកប្រកាសថាព្រះបានឆ្លើយតបសេចក្តីអធិស្ឋានរបស់គាត់។ ការឆ្លើយតបចំពោះសេចក្តីអធិស្ឋាននេះគឺជាពេលដែលមានការផ្លាស់ប្តូររបស់ទំនុកដំកើងហើយនាំទៅដល់ផ្នែកបន្ទាប់ទៀត។

**ខ. ២២-៣១ ពិធីបុណ្យសរសើរតម្កើងសកល**

ឥឡូវនេះពាក្យរបស់អ្នកនិពន្ធទំនុកដំកើងត្រឡប់ពីការឈឺចាប់និងការបោះបង់ចោលទៅជាការសរសើរតម្កើងនិងសេចក្តីសង្ឃឹមវិញ។ គាត់ដឹងថាគាត់នឹងរស់នៅដើម្បីសរសើរដល់សេចក្តីសង្គ្រោះរបស់ព្រះ ចែករំលែកអាហារយញ្ញបូជានៃការអរព្រះគុណជាមួយអ្នកក្រនិងអ្នកខ្វះខាត។ រំពេចនោះវាគឺជាពេលធ្វើពិធីបុណ្យសំរាប់អ៊ីស្រាអែល (ខ. ២២-២៦) និងសំរាប់ពិភពលោកទាំងមូល (ខ.២៧-៣១)៖ អ្នកក្រត្រូវបានអញ្ជើញចូលរួមពិធីស៊ីលៀង (ខ.២៦) ទាំងអស់គ្នាត្រូវបានអញ្ជើញចូលរួម (ខ. ២៩) ហើយព្រះបន្ទូលនឹងចេញទៅកាន់គ្រប់ពូជពង្សមនុស្សនាពេលអនាគត (ខ. ៣០, ៣១)។

**ខ. ២២** ម្តងទៀត យើងឃើញថាដាវីឌមិនរអ៊ូរទាំដោយសារតែការរងទុក្ខរបស់គាត់នោះទេ ប៉ុន្តែគាត់សរសើរតម្កើងព្រះនៅក្នុងពួកជំនុំវិញ។ ហេព្រើ ២.១២ ដកស្រង់ខ. ២២ ហើយថ្លែងដូចជាការដកស្រង់របស់ព្រះយេស៊ូវដែរ។ ជាចុងក្រោយនេះពិតជាការដកស្រង់មួយសំរាប់ព្រះយេស៊ូវ ពីព្រោះខនេះណែនាំអំពីផ្នែកមួយនៃទំនុកដំកើងនេះដែលហៅអ៊ីស្រាអែលនិងពិភពលោកមកកាន់ពិធីស៊ីលៀងរបស់ព្រះមែស៊ី (អេសាយ ២៥.៦-១០ក, វិវរណៈ ១៩:៩)។ នៅក្នុងបរិបទនៃហេព្រើរ ២ ព្រះយេស៊ូវ «មិនខ្មាសនឹងហៅគេជាបងប្អូនទេ» ហើយដូច្នេះទ្រង់ឈរ *នៅកណ្តាល* ។

**ខ. ២៣** បន្ទាប់ពីការប្រកាសថាគាត់នឹងសរសើរតម្កើងព្រះ គាត់ដាស់តឿនមនុស្សសុចរិតឲ្យសរសើរតម្កើងព្រះផងដែរ។ អស់អ្នកដែលត្រូវបានហៅឲ្យសរសើរតម្កើងព្រះគឺជា *ពូជយ៉ាកុប*។ ការនេះបង្កើតជាផ្ទៃរឿងសំខាន់មួយពេញក្នុងព្រះគម្ពីរ។ ចាប់ពីលោកុប្បត្តិ ៣:១៥ យើងឃើញថានឹងមានសេចក្តីខ្មាំងនឹងគ្នារវាងពូជរបស់សត្វពស់នឹងពូជរបស់ស្ត្រី។ ផ្ទៃរឿងនេះមានពេញក្នុងព្រះគម្ពីរទាំងមូល ហើយត្រូវបានឃើញច្បាស់នៅក្នុងទំនុកដំកើងនេះនៅពេលពូជរបស់សត្វពស់ (ពួក

ខ្មាំងសត្រូវរបស់ព្រះ) គៀបសង្កត់ដាវីឌ។ ប៉ុន្តែមានពូជពង្សសុចរិតដែលជាពូជនៃសេចក្តីសន្យាដែលនៅក្នុងព្រះគម្ពីរសញ្ញាចាស់ត្រឡប់ជា*ពូជរបស់យ៉ាកុប*។ ពួកគេគឺជាប្រជារាស្ត្ររបស់ព្រះដែលចូលរួមពិធីបុណ្យនេះ។ ប៉ុន្តែក្នុងខបន្ទាប់ៗមកទៀត យើងឃើញថាការអញ្ជើញមកចូលរួមពិធីបុណ្យនេះទៅដល់ពូជពង្សទាំងអស់នៅលើផែនដី។ នេះត្រូវបានបំពេញសំរេចនៅក្នុងព្រះគម្ពីរសញ្ញាថ្មីដែលបើកសំដែងថា ព្រះគ្រីស្ទគឺជាពូជរបស់ស្ត្រីដែលកិនក្បាលសត្វពស់ ហើយអស់អ្នកដែលជឿដល់ទ្រង់ ទាំងសាសន៍យូដានិងសាសន៍ដទៃ នឹងចូលរួមពិធីស៊ីលៀងរបស់ព្រះមែស៊ី។

**ខ. ២៤** ទោះបើពួកខ្មាំងសត្រូវរបស់គាត់មើលងាយដាវីឌ ហើយពួកខ្មាំងសត្រូវរបស់ព្រះគ្រីស្ទមើលងាយទ្រង់និងឈើឆ្កាងរបស់ទ្រង់ ការនេះផ្ទុយជាមួយនឹងព្រះ។ អស់អ្នកដែលជារបស់ព្រះជាម្ចាស់បានឃើញសិរីល្អរបស់ព្រះនៅក្នុងការរងទុក្ខរបស់ព្រះគ្រីស្ទ ហើយនឹងទ្រាំទ្រយ៉ាងអត់ធ្មត់ក្នុងការរងទុក្ខផងដែរ ដោយដឹងថាព្រះមិនមើលងាយការរងទុក្ខរបស់យើងនោះឡើយ។

**ខ. ២៥** *ទ្រង់ជាដើមហេតុ។* ព្រះអម្ចាស់គឺជាប្រភពនិងជាអ្នកទទួលការសរសើរតម្កើង។

*បំណន់...ក្រ (ខ.២៦)*។ ខនេះផ្តល់កន្លែងកើតហេតុនៃខទាំងនេះ ពីព្រោះក្រឹត្យវិន័យបានលើកទឹកចិត្តអស់អ្នកដែលបានលាបំណន់ទៅកាន់ព្រះដោយព្រោះព្រះអង្គបានឆ្លើយសេចក្តីអធិស្ឋានរបស់ពួកគេ ឲ្យបំពេញសម្រេចសម្បថជាមួយនឹងយញ្ញបូជាដែលមានពិធីស៊ីលៀងមួយ (ខ. ២៦) ដែលអាចធ្វើអស់រយៈពេលពីរថ្ងៃ (លេវី ៧:១៦, ចោទិយកថា ១៦:១០-១២)។

**ខ. ២៧** ព្រះបានសន្យាថាគ្រប់ជាតិសាសន៍នឹងបានព្រះពរតាមរយៈអ័ប្រាហាំនិងពូជរបស់អ័ប្រាហាំ។ទំនុកដំកើងនេះបង្ហាញពីរបៀបដែលព្រះនឹងប្រទានពរដល់គ្រប់ជាតិសាសន៍តាមពូជរបស់អ័ប្រាហាំ។ តាមរយៈការរងទុក្ខរបស់ពូជពង្សរបស់ព្រះមែស៊ី ចាប់ពីចុងបំផុតផែនដីនឹងនឹកចាំហើយងាកបែរមករកព្រះអម្ចាស់។ សំរាប់ការបំពេញសម្រេចនៃ *ហើយពូជពង្សនៃនគរទាំងឡាយនឹងថ្វាយបង្គំនៅចំពោះទ្រង់* សូមមើល (ភីលីព ២:១១, វិវរណៈ ៥:៩)។

**ខ. ២៨** វាជារឿងត្រឹមត្រូវដែលត្រូវថ្វាយបង្គំនៅចំពោះព្រះ ពីព្រោះទ្រង់គ្រប់គ្រងលើជាតិសាសន៍ទាំងអស់។ ដូចគ្នាដែរ ព្រះគម្ពីរសញ្ញាថ្មីបង្រៀនថា វាជាការត្រឹមត្រូវដែលត្រូវថ្វាយបង្គំនៅចំពោះព្រះយេស៊ូវហើយប្រកាសថាទ្រង់គឺជាព្រះអម្ចាស់ ពីព្រោះគ្រប់ទាំងអំណាចនៅលើស្ថានសួគ៌និងផែនដីត្រូវបានប្រគល់មកឲ្យទ្រង់ហើយ។

**ខ. ២៩** អត្ថន័យទូទៅគឺថា មនុស្សទាំងអស់ត្រូវបានស្វាគមន៍។ យើងមិនច្បាស់ថា*ធូលី*គឺជាពាក្យប្រៀបសំរាប់ភាពក្រីក្រ (ទំនុកដំកើង ១១៣.៧ ប្រៀបធៀប ១សាំយ៉ូអែល ២:៨) ឬសំរាប់សេចក្តីស្លាប់នោះទេ (ទំនុកដំកើង ៣០:៩ ប្រៀបធៀប យ៉ូប ៧:២១)។

**ខ. ៣០-៣១** *ពូជពង្ស* នៅពេលអស់អ្នកដែលស្លាប់ថ្វាយបង្គំនៅចំពោះទ្រង់ ពូជពង្សរបស់អ្នកស្លាប់ដែលនៅរស់នឹងបន្តបម្រើទ្រង់ទៅទៀត។ ការនេះនឹងបន្តជារៀងរហូត។ វាគឺជាសេចក្តីពិតស្រដៀងនឹងព្រះយេស៊ូវមានបន្ទូលថា ទ្វារស្ថានឃុំព្រលឹងមនុស្សស្លាប់នឹងមិនដែលឈ្នះពួកជំនុំរបស់ទ្រង់ឡើយ (ម៉ាថាយ ១៦:១៨)។

*គេនឹងថ្លែងប្រាប់ពីព្រះអម្ចាស់ដល់តំណរមនុស្សក្រោយតទៅ* ផលប្រយោជន៍ដែលមកពីការរងទុក្ខនិងជ័យជម្នះរបស់ព្រះមែស៊ីនឹងជាសំរាប់មនុស្សគ្រប់ប្រភេទទាំងអស់ (ខ. ២៩) ហើយសំរាប់តំណរមនុស្សទាំងអស់។ ដូច្នេះ ខ. ២៩-៣០ ប្រាប់ជាមុនអំពីការប្រកាសអំពីដំណឹងល្អទៅកាន់គ្រប់ជាតិសាសន៍រហូតដល់ព្រះគ្រីស្ទយាងត្រឡប់មកវិញ។ ការប្រកាសព្រះបន្ទូលដែលជាដំណឹងល្អរបស់ព្រះគ្រីស្ទគឺជារបៀបសំខាន់មួយដែលពួកជំនុំនឹងបន្ត ហើយទ្វារស្ថានឃុំព្រលឹងមនុស្សស្លាប់នឹងមិនដែលយកឈ្នះបានឡើយ។

*ប្រាប់ពីព្រះអម្ចាស់...ដែលទ្រង់បានធ្វើការនោះ*។ ព្រះរាជសារកំពុងចេញទៅគឺ «ការអស្ចារ្យរបស់ព្រះ» (កិច្ចការ ២:១១) ។ អ្នកខ្លះមើលឃើញអំពីទំនាក់ទំនងរវាងពាក្យចុងក្រោយរបស់ទំនុកដំកើងនេះ «ទ្រង់បានធ្វើការនោះ» ជាមួយនឹងបន្ទូលរបស់ព្រះយេស៊ូវនៅលើឈើឆ្កាង «ការស្រេចហើយ» (យ៉ូហាន ១៩:៣០)។

**ការអនុវត្ត**

ទំនាក់ទំនងរវាងទំនុកដំកើងនេះនឹងឈើឆ្កាងរបស់ព្រះគ្រីស្ទធ្វើឲ្យការអនុវត្តមានភាពច្បាស់លាស់ បើទោះជាយើងត្រូវគិតអំពីវាយ៉ាងជ្រៅក៏ដោយ។ ទណ្ឌកម្មចុងក្រោយសំរាប់អំពើបាបគឺជាសេចក្តីស្លាប់ហើយនិងការបោះបង់ចោលអស់កល្បជានិច្ចរបស់ព្រះ។ វាត្រូវដាច់ចេញពីព្រះនៅក្នុងកន្លែងនៃសេចក្តីវិនាសអស់កល្បដែលជាស្ថាននរក (២ថែស្សាឡូនិច ១:៩)។ ដើម្បីឲ្យព្រះយេស៊ូវទទួលយកទណ្ឌកម្មនោះ ទ្រង់ត្រូវតែរងទុក្ខការសុគតហើយត្រូវព្រះបោះបង់ចោល។ គឺជាព្រះដែលបាននាំព្រះមែស៊ីទៅកាន់ការសុគត (ខ. ១៥)។ ទំនុកដំកើងនេះបង្ហាញយ៉ាងច្បាស់ថា លទ្ធផលនៃការសុគតរបស់ព្រះមែស៊ីគឺជាសេចក្តីសង្គ្រោះសំរាប់តំណរមនុស្សទាំងអស់នៅលើផែនដី ដែលបំពេញសម្រេចសេចក្តីសន្យារបស់ព្រះតាមរយៈអ័ប្រាហាំ។ ព្រះរាជសារនេះត្រូវតែចេញទៅកាន់ពិភពលោកទាំងមូលនិងតំណរមនុស្សទាំងអស់។ គ្មាននរណាម្នាក់ដែលមិនត្រូវបានអញ្ជើញនោះទេ។ ដូច្នេះ ការអនុវត្តគ្រឹះចេញពីទំនុកដំកើងនេះគឺ យើងត្រូវដាក់ការទុកចិត្តរបស់យើងលើដំណឹងល្អរបស់ព្រះយេស៊ូវ ហើយចែកចាយដំណឹងល្អទៅកាន់ពិភពលោកទាំងមូល។ យើងគួរតែមានអំណរនិងការសរសើរតម្កើងចំពោះទ្រង់សំរាប់អ្វីដែលទ្រង់បានធ្វើ។ លើសពីនេះ ទោះបើការរងទុក្ខរបស់ព្រះមែស៊ីខុសពីការរងទុក្ខរបស់យើងក៏ដោយ (យើងមិនស្លាប់ដើម្បីសង្គ្រោះអ្នកដទៃចេញពីអំពើបាបរបស់ពួកគេទេ) ក៏គំរូនៃការទុកចិត្តនៅក្នុងការរងទុក្ខរបស់ទ្រង់ផ្តល់គំរូល្អមួយសំរាប់ឲ្យយើងដើរតាមដែរ។

**សំរាប់ការសិក្សាបន្ថែម**

១. សូមអានអេសាយ ៥៣។ តើការសុគតរបស់ព្រះយេស៊ូវបានបំពេញសំរេចទំនាយនេះដោយរបៀបណា?

២. សូមអាន១កូរិនថូស ២.២ និងកាឡាទី ៦.១៤។ តើបទគម្ពីរទាំងពីរនេះបង្រៀនអ្វីអំពីឈើឆ្កាង?

**Bibliography**

Beale, G.K., D.A. Carson, Ed. (2007), *Commentary on the New Testament Use of the Old Testament*, Grand Rapids, MI; Nottingham, England: Baker Academic

*Biblia Hebraica Stuttgartensia: With Westminster Hebrew Morphology.* 1995. Stuttgart; Glenside PA: German Bible Society; Westminster Seminary.

Calvin, J., & Anderson, J. (2010). *Vol. 1: Commentary on the Book of Psalms*. Bellingham, WA: Logos Bible Software.

Carson, D.A., R. T. France, J. A. Motyer & G. J. Wenham, Ed. (1994), *New Bible commentary: 21st century edition*, (4th ed.) Leicester, England; Downers Grove, IL: Inter-Varsity Press.

Ellsworth, R. (2006). *Opening up Psalms*. Opening Up Commentary. Leominster: Day One Publications.

Garrett, D. A. (1998). 'The Poetic and Wisdom Books', in D. S. Dockery (Ed.), *Holman concise Bible commentary* (D. S. Dockery, Ed.). Nashville, TN: Broadman & Holman Publishers.

Henry, M. (1994), *Matthew Henry's commentary on the whole Bible*, Peabody: Hendrickson.

Jamieson, R., Fausset, A. R., & Brown, D. (1997). *Commentary Critical and Explanatory on the Whole Bible*. Oak Harbor, WA: Logos Research Systems, Inc.

Keil, C. F., & F. Delitzsch, (1996). *Vol. 5: Commentary on the Old Testament*. Peabody, MA: Hendrickson.

Kidner, D. (1975). *Vol. 16: Psalms 73–150: An Introduction and Commentary*. Tyndale Old Testament Commentaries. Nottingham, England: Inter-Varsity Press.

Knowles, A. (2001). *The Bible guide (1st Augsburg books ed.)*. Minneapolis, MN: Augsburg.

Matthews, V. H., M. W. Chavalas & J.H. Walton (2000), *The IVP Bible background commentary: Old Testament*, Downers Grove, IL: InterVarsity Press.

Wiersbe, W. W. (1993). *Wiersbe's Expository Outlines on the Old Testament*. Wheaton, IL: Victor Books.